# ជីវិត Life

"ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យមាន
ជីវិតយ៉ាងបរិបូរណ៍"។
(យ៉ូហាន:១០,១០)

សកម្មភាពព្រះសហគមន៍ភូមិភាគភ្នំពេញ
លេខ៩ សម្រាប់ ថ្ងៃទី០១-៣១ ខែសីហា ឆ្នាំ២០១២

## សិស្សសាលាអប់រំជំនឿសន្ត ចាស្ទីនធ្វើទស្សន កិច្ចសិក្សានៅប្រទេសវៀតណាម ថៃ និងឡាវ



**អេម៉ានូអែល**
សំឡេងព្រះសហគមន៍កាតូលិក **FM 102.5 Mhz**
ម៉ោង ២:០០ - ៣:០០ រាល់ថ្ងៃសុក្រ

**ខ្ញុំត្រូវការអ្នក (I NEED YOU)**
រាល់ថ្ងៃអង្គារ **FM 99.5 Mhz**
ម៉ោង ១០:០០ - ១១:០០ ព្រឹក

# សូមលើកតម្កើងព្រះអម្ចាស់



បងប្អូនជាទីស្រលាញ់

យើងទើបតែបាន បញ្ចប់សំណាក់ធម៌ក្រុមអេម៉ាណូអែលថ្មីៗនេះ។ មានយុវជនប្រមាណជា៤៥នាក់មក ពីភូមិភាគទាំងបីបានចូលរួម។

ព្រះបន្ទូលដំណឹងល្អរបស់សន្តម៉ាកុសដែលបានណែនាំក្នុងកម្មវិធីសំណាក់ធម៌នោះគឺ៖ "ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ព្រះអង្គត្រូវការខ្ញុំ ហើយព្រះអង្គបានចាត់ខ្ញុំឲ្យទៅ" ។ ពួកគេម្នាក់ៗបានយកពេលវេលាមួយដើម្បីរិះគិតពិចារណាលើសំនួរដ៏សំខាន់មួយដែលព្រះយេស៊ូបានសួរគឺ៖ ចុះអ្នកវិញតើអ្នកថាខ្ញុំជានណា?

ពេញមួយឆ្នាំ យើងបានព្យាយាមដើរតាមការបង្រៀនរបស់ព្រះយេស៊ូ។ពេញមួយជីវិតរបស់យើង យើងត្រូវតែធ្វើយ៉ាងណាដើម្បីឲ្យទំនាក់ទំនងរបស់យើងកាន់តែស៊ីជម្រៅនឹងព្រះគ្រីស្ត។

ប៉ុន្មានខែនេះគឺជាពេលវិស្សមកាលរបស់សិស្ស-និស្សិតពីការសិក្សា ហើយវាជាពេលវេលាមួយដ៏ល្អដើម្បីជួបជុំក្រុមយុវជន កុមារកាយឫទ្ធិ គ្រូអប់រំជំនឿ លោកបូជាចារ្យ។ ជាងនេះទៅទៀតជាពេលវេលាមួយដើម្បីឲ្យនិស្សិតសាលាអប់រំជំនឿនៃសន្តចាស្ទីនចេញទៅទស្សនកិច្ចសិក្សាព្រះសហគមន៍នានានៅប្រទេសថៃ ឡាវ និងវៀតណាម។

ព្រឹត្តិការណ៍ទាំងនេះបានជួយយើងដើម្បីឲ្យយល់កាន់តែច្បាស់ អំពីព្រះសហគមន៍នៅកន្លែងរបស់យើង។

យើងពិតជាមានអំណរជាខ្លាំងដោយយើងជាសមាជិកម្នាក់របស់ប្រជាជនព្រះជាម្ចាស់។ សូមឲ្យអំណរនេះចេញមកនៅថ្ងៃទី១៥ខែសីហាជាមួយព្រះនាងម៉ារី៖ សូមលើកតម្កើងព្រះអម្ចាស់

លោកអភិបាលអូលីវីយេ ឆ្មីតអឺស្លែរ
ជាអភិបាលរបស់បងប្អូន

MAGNIFICAT

Dear friends,

The retreat of the group Emmanuel is just finished. There are 45young men from the three dioceses.

This is the Gospel of Mark who accompanied us during these days of prayer: God calls me, God needs me, and God sends me. Each one has taken time of refection about the very important question of Jesus: "for you, who am I?"

Throughout this year, we tried to put ourselves to the school of Jesus. Throughout our lives, we must deepen our personal relationship with Christ.

These months is the time of holidays and it a good time for the gatherings of youths, scouts, catechists, priests but also for students of the School of the Faith - St. Justin who went to discover the churches of Laos, Vietnam and Thailand.

All these events help us to better understand our place in the heart of the Church.

May we with our little Therese exclaimed: "in the heart of the Church, my Mother, I have found my place: I will be the Love! "

How happy we are to be a member of the People of God. May this joy come out on the August 15 with Mary: Magnificat!

+ Olivier Schmitthaeusler
Your bishop

# ក្រុមបេះដូងសាវ័កជាពន្លឺមួយសម្រាប់អ្នកឃ្លាតឆ្ងាយពីព្រះជាម្ចាស់

យុវជនប្រមាណជា ១២នាក់បាន រួបរួមគ្នាបង្កើតបានជាក្រុមមួយដែលមានឈ្មោះថា "ក្រុមបេះដូងសាវ័ក"។ នៅពាក់កណ្តាលឆ្នាំ២០១១ មានយុវជនមួយចំនួនដែលបានជួបជុំគ្នា ដើម្បីជួយគ្រីស្តបរិស័ទ និងជាពិសេសគឺយុវជនដែលនៅឆ្ងាយពីព្រះជាម្ចាស់ ឲ្យគេស្គាល់កាត់តែជិតស្និតនឹងព្រះយេស៊ូវិញ ហើយបានទទួលការជួយគាំទ្រពីសំណាក់លោកបូជាចារ្យ គ្រីស្តុប និងបងស្រីប៉ោឡា។។ សកម្មភាពចម្បងរបស់គេ គឺ ការអធិដ្ឋាន(តេហ្សេ) ការចែករំលែក និងសកម្មភាពផ្សេងៗ និងសួរសុខទុក្ខយុវជនព្រះសហគមន៍នានានៅតាមមណ្ឌលសកម្មភាពទន្លេមេគង្គ និងមណ្ឌលសកម្មភាពទន្លេបាសាក់។ ដោយយោងតាមចេតនាអារម្មណ៍របស់សាវ័កពីដើម ដែលគេបានស្គាល់និងនៅជាមួយព្រះយេស៊ូ ដូច្នេះព្រះយេស៊ូបានភ្ជាប់ជាមួយពួកគេ នាំឲ្យពួកគេចេញទៅចែករំលែកនិងណែនាំអ្នកដទៃឲ្យ ស្គាល់ព្រះយេស៊ូ។ ក្រុមនេះជឿជាក់ថាព្រះវិញ្ញាណដ៏វិសុទ្ធ គឺ ជាកម្លាំងពិសេសដែលជួយគេក្នុងគ្រប់សកម្មភាព។ ជាការពិតណាស់ បើគ្មានព្រះវិញ្ញាណទេនោះយើងមិនអាចធ្វើអ្វីបានឡើយ។ ក្រោយពីទទួលបានកម្លាំង និងការគាំទ្រយ៉ាងពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ ក្រុមបេះដូងសាវ័កប្រៀបបីដូចជាទៀន ដ៏តូចមួយដែលកំពុងឆេះឡើងក្នុងទីងងឹត ដើម្បីបំភ្លឺអស់អ្នកដែលវង្វេងក្នុងភាពងងឹត បានស្គាល់ពន្លឺនិងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ត ដោយរីករាយ ស្រលាញ់ និងបំរើ។

ក្រុមបេះដូចសាវ័កគឺ មានតែនៅមណ្ឌលសកម្មភាពទន្លេបាសាក់ និងមណ្ឌលសកម្មភាពទន្លេមេគង្គតែប៉ុណ្ណោះ។

ដោយសារហេតុនេះហើយ ទើបកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ក្រុមបេះដូងសាវ័ក បានជួបប្រជុំជាមួយលោកអភិបាលអូលីវីយេ នៅគេហដ្ឋានរបស់លោកផ្ទាល់។

*សុជារិទ្ធិ*



# ការប្រលងបញ្ចប់របស់និស្សិតឆ្នាំទី២ ឆ្នាំនេះខុសពីឆ្នាំមុនៗ

សាលាបច្ចេកទេស ដុនបូស្កូ ខេត្តព្រះសីហនុ បានធ្វើការប្រលងបញ្ចប់ឆ្នាំសិក្សារបស់សិស្ស និស្សិត ឆ្នាំទី២ នៅថ្ងៃទី២-៣ ខែសីហា ឆ្នាំ២០១២ ដែលមានការចូលរួម ដោយក្រសួងការងារផងដែរ។

លោកគ្រូ ញ៉ាន គឿន បានមានប្រសាសន៍ថា ឆ្នាំនេះការប្រលងមានភាពខុសប្លែកពីឆ្នាំមុនៗ ដោយតម្រូវឲ្យសិស្សទាំងអស់ចេញទៅធ្វើការជាមុន ទើបមកប្រលងវិញ ដែលខុសពីឆ្នាំមុនៗ សាលាធ្វើការប្រលងនៅចុងខែមិថុនា ជារៀងរាល់ឆ្នាំ។

យុវសិស្ស វ៉ុន សុភាព ជាសិស្សផ្នែកអគ្គិសនី បាននិយាយថា រូបគាត់ក៏ដូចជាសិស្សនិស្សិតដទៃដែរ មានការពិបាកណាស់ក្នុងការសុំច្បាប់ ក៏ដូចជាការធ្វើដំណើរផងដែរ ព្រោះមាននិស្សិតខ្លះត្រូវទៅធ្វើការ នៅតាមបណ្តាខេត្តឆ្ងាយៗ។ គាត់បានសំណូមពរ ឲ្យឆ្នាំក្រោយៗ សុំឲ្យមានការប្រលងមុននឹងចេញទៅរកការងារ។

*សៀកលាវ*

## DBTS-Sihanoukville Students Find Difficulties in Final Exam Procedure

The second year students at Don Bosco Technical School in Sihanoukville took the final exam on August 2-3. However, they found the process more difficult this year. Mr. Nhan Phoeurn, a teacher, said that this year, the school required all the 2nd year students to leave for their internship or practicum before coming back for the final examinations. While the previous years, they did the final exam before leaving the school for their practicum.

Mr. Vun Sopheap, an electrical student, said he and many of his friends found it difficult to ask permission from the work place. "We got a job but it was far from Sihanoukville. We spent more than a day travelling. We would like to take the final exam before we start working, like before," said Sopheap.



# លោកបូជាចារ្យ គ្រីស្តុបវិលត្រលប់ទៅប្រទេសបារាំងវិញ





បន្ទាប់ពីបានបម្រើព្រះសហគមន៍ប្រទេសកម្ពុជាអស់រយៈពេល៥ឆ្នាំកន្លងមក លោកបូជាចារ្យគ្រីស្តុប ត្រូវបានវិលត្រលប់ទៅប្រទេសបារាំងវិញហើយ។

លោកគ្រីស្តុបបានឲ្យដឹងថាលោកពិតជាមិនអាចបំភ្លេចជីវិតនៅប្រទេសកម្ពុជាបានទេទោះបីជាគាត់ត្រលប់ទៅប្រទេសបារាំងវិញក៏ដោយ។ លោកបានរៀបរាប់ថា កាលដំបូងឡើយជីវិតលោកជួបប្រទះនឹងការលំបាកជាខ្លាំងព្រោះលោកត្រូវតែធ្វើកិច្ចការជាច្រើនដែលខុសប្លែកដែលលោកពុំដែលបានជួបប្រទះ ដូចជាភាសា អក្សរ ម្ហូបអាហារ វប្បធម៌ និងអាកាសធាតុជាដើម។ តែនៅទីបញ្ចប់ការលំបាកទាំងនោះធ្វើអោយគាត់ទទួលបានភាពកក់ក្តៅ និងទទួលបានសេចក្តីស្រលាញ់ដ៏ពេញលេញមួយពីសំណាក់បងប្អូនគ្រីស្តបរិស័ទជាពិសេសក្មេងៗ។ ឆ្លងតាមបទពិសោធនៃការបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា លោកពិតជាពេញចិត្តនឹងរបៀបនៃការប្រកាសជំនឿ។ លោកឃើញថាព្រះសហគមន៍ខ្មែរទើបតែកើតឡើងមែន តែគ្រីស្តបរិស័ទមានសេរីភាពគ្រប់គ្រាន់ដើម្បីរក្សាជំនឿរបស់ខ្លួន។ ជាងនេះទៅទៀតគ្រីស្តបរិស័ទហាក់បីដូចជាបើកចិត្តទូលាយដើម្បីទទួលស្វាគមន៍គ្នាទៅវិញទៅមក។ បទពិសោធន៍នេះធ្វើឲ្យលោក រកឃើញថាព្រះយេស៊ូនៅគ្រប់ទីកន្លែង ហើយព្រះអង្គកំពុងតែរង់ចាំទទួលលោក។ លោកបូជាចារ្យគ្រីស្តុបនឹងទទួលខុសត្រូវព្រះសហគមន៍មួយនៅទីក្រុង ម៉ាកសី ប្រទេសបារាំង។

លោកបូជាចារ្យ គ្រីស្តុបបានមកដល់ប្រទេសកម្ពុជានៅឆ្នាំ ២០០៧។ លោកបានទទួលអគ្គសញ្ញាជាបូជាចារ្យនៅឆ្នាំ ១៩៩៥ ។

*លីលី*

## Father Christoph Returns to France

After five years working in Cambodia, Fr. Christoph, an associate priest of the MEP, got back to serve the church in France. Before leaving, he said, “It will be very hard to forget the time that I spent in Cambodia. When I first arrived, it seemed very difficult to face all the obstacles such as language, food, culture and weather. But after 5 years, they have all become part of my daily life. People are very friendly and they are ready to help me in whatever I need. This gives me warmth and great love. The Cambodian church is young, but I have observed that the Christians are very free to practice their faith and they are truly open-hearted in welcoming each other.

Fr. Christoph came to Cambodia in 2007 and he was ordained in 1995

# កុមារកាយឫទ្ធិចូលរួមសំអាតបរិស្ថាននៅរមណីយដ្ឋានភ្នំជីសូរ

ក្រុមកាយឫទ្ធិប្រមាណជាជាង៥៥នាក់នៅព្រះសហគមន៍ព្រៃកប្បាសបានចូលរួមសំអាតអនាម័យ និងបរិស្ថាននៅរមណីដ្ឋានភ្នំជីសូខេត្តតាកែវ។

លោក រ័ត្ន ចន្ថា ដែលជាអ្នកណែនាំក្រុមកាយឫទ្ធិ នៅក្នុងព្រះសហ-គមន៍ព្រៃកប្បាស បានមានប្រសាសន៍ថា កម្មវិធីនេះត្រូវបានរៀបចំឡើងគឺ ក្នុងគោលបំណងចង់ឲ្យកុមារកាយឫទ្ធិទាំងអស់ ចេះស្រឡាញ់ ការពារ និងថែរក្សាបរិស្ថាន និងចេះសាមគ្គីគ្នា ក្នុងការសំអាតបរិស្ថាន ដែលនៅជុំវិញខ្លួនរបស់ពួកគ។ បន្ទាប់ពីកម្មវិធីសំអាតបរិស្ថានហើយ កុមារកាយឫទ្ធិទាំងនោះបានទទួលទានអាហារថ្ងៃត្រង់ជាមួយគ្នា ដើរទស្សនាប្រាសាទ និងចូលរួមលេងល្បែងកំសាន្តមួយចំនួនដូចជា៖ ដណ្តើមស្លឹកឈើ បោះបាល់ហៅឈ្មោះចំប៉ាចំប៉ី ជាដើម ។

## Scouts from Prey Kabas Clean Chisor Mountain Tourism Site

About 55 scouts, including their leaders, cleaned the tourism site at Chisor mountain in Takeo.

Mr. Roth Chantha, scout leader, said that this program was made to let the kids love, protect and be concerned about the environment where they were living. After cleaning they enjoyed lunch and some games.

***Nimet***







# ព្រះសហគមន៍ព្រៃកប្បាសនាំអ្នកជម្ងឺភ្នែក ៧៥នាក់ ទៅព្យាបាលនៅមន្ទីរពេទ្យភ្នែកខេត្តតាកែវ







អ្នកជម្ងឺភ្នែក៧៥នាក់ត្រូវបានព្រៃសហគមន៍ព្រៃកប្បាសជូនទៅព្យាបាលនៅមន្ទីរពេទ្យភ្នែកតាកែវចាប់តាំងពីដើមខែឧសភារហូតដល់ ខែមិថុនា។

កញ្ញា ម្រេច វ៉ាន់នាថ ដែលជាអ្នកស្ម័គ្រចិត្ត នាំអ្នកជម្ងឺទៅមន្ទីរពេទ្យភ្នែក បានមានប្រសាសន៍ថា អ្នកជម្ងឺ ដែលព្រះសហគមន៍បានបញ្ជូនទៅនោះ ជាប្រជាជនទីទ័លក្រខ្វះលទ្ធភាពទៅទទួលការព្យាបាលនៅមន្ទីរពេទ្យ ភ្នែកខេត្តតាកែវដោយខ្លួនឯង។ កញ្ញាបានប្រាប់ឲ្យដឹងដែរថា ក្នុងចំណោមអ្នកជម្ងឺទាំង ៧៥ នាក់នោះ មាន ២១នាក់បានទទួលការព្យាបាលដោយថ្នាំ ៤២នាក់ទទួលបានវ៉ែនតា អ្នកត្រូវវះកាត់ និងបកភ្នែកចំនួន ៥ នាក់។

លោក ព្រំ ចាន់ ជាអ្នកជម្ងឺភ្នែក ហើយបានទទួលការវះកាត់បានមានប្រសាសន៍ថា លោកពិតជាត្រេកអរជាខ្លាំងនៅពេលដែលភ្នែករបស់គាត់បានជាសះស្បើយ។ លោកបានបន្តទៀតថា លោកមានអារម្មណ៍ថាដូចជាកើតឡើងវិញម្តងទៀតអញ្ចឹង។

*និម្រិត*

## Prey Kabas Community Brings 75 Patients to Eye Hospital in Takeo

A total of 75 patients from Prey Kabas community were brought to the eye hospital in Takeo during these few months. Ms. Vanneat, a volunteer who brought in the patients, said that the church is playing a very important role by bringing hope to the poor in her community. She added that among the 75 patients, 21 received medical care, 42 received glasses and the other 5 underwent eye surgery. Mr. Prom Chan, who went through an eye operation, said he was indescribably glad as his eyes got normal. "I feel like I was born again," said Mr. Phom Chan

# ក្រុមអ្នកស្ម័គ្រចិត្តអង្គការ Coup De Pouce សាងសង់អគារនៅព្រះសហគមន៍ព្រៃប្រស់





ក្រុមអ្នកស្ម័គ្រចិត្តមកពីអង្គការ Coup De Pouce ១៣នាក់ បានមកព្រះសហគមន៍មណ្ឌលសកម្មភាពកំពតពីរសប្តាហ៍ដើម្បី ធ្វើការសាងសង់អគារមួយសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពទូទៅ ក្នុងព្រះសហគមន៍ព្រៃប្រស់។

លោក ចន លូកាជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ មណ្ឌលសកម្មភាពកំពត មានប្រសាសន៍ថាក្រុមអ្នកស្ម័គ្រចិត្តមក ពីអង្គការនេះ មានបេសកម្មដើម្បីជួយកសាង។ លោកបន្តថា អគារ ដែលពួកគេបានសាងសង់នៅព្រះសហគមន៍ព្រៃប្រស់នេះ ជា អគារតូចល្មម តែទោះបីជាយ៉ាងណាក៏ដោយក៏វាពិតជាមានសារៈ



សំខាន់ខ្លាំងណាស់ដើម្បីមប្រើសម្មភាពនានាក្នុងព្រះសហគមន៍ ដូចជា កន្លែងស្នាក់នៅពេលមានភ្ញៀវ ទទួលអ្នកជម្ងឺ ជាបណ្ណាល័យ និងការជួបជុំផ្សេងៗទៀត។ អង្គការ Coup De Pouce គឺជាសមាគមសប្បុរសជននៅប្រទេសបារាំង។ ជារៀង រាល់ឆ្នាំអង្គការនេះបានបញ្ជូនយុវជនស្ម័គ្រចិត្តដើមកជួយសាង សង់ផ្ទះ អគា សាលារៀនជូនប្រជាជនក្រីក្រនៅប្រទេសកម្ពុជា។

ព្រះសហគមន៍ព្រៃប្រស់ ស្ថិតនៅខណ្ឌព្រៃនប់ ខេត្តព្រះ សីហនុ។

## Volunteers from Coup De Pouce Help Construct Building for Prey Pros Community

A group of 13 volunteers came to Kompot to build a building for the Prey Pros community in Sihanouk province, which is part of the Kompot pastoral center.

Fr. Gianluca Tavola, in charge of Kompot pastoral center, said this building will be very important for Prey Pros as it is a small community. “The building could be useful for many kinds of gatherings and for a library,” said Fr. Gianluca

# មណ្ឌលសកម្មភាពភ្នំពេញបិទវគ្គសិក្ខាសាលាគ្រូអប់រំជំនឿប្រចាំឆ្នាំ

សិក្ខាសាលាបិទវគ្គសម្រាប់គ្រូអប់រំជំនឿនៅមណ្ឌលសកម្មភាពភ្នំពេញខាងជើងត្រូវបានធ្វើឡើងនៅព្រះសហគមន៍ផ្សារតូចកាលពីថ្ងៃទី២២ ខែកក្កដា កន្លងទៅនេះ។

ដោយយោងទៅតាមលោក បូជាចារ្យប្រ៊ុយណូ ដែលទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើងបានឲ្យដឹងថា សកម្មភាពខាងអប់រំជំនឿគឺត្រូវបានយកចិត្តទុកដាក់បំផុតសម្រាប់មណ្ឌលសកម្មភាពដែលលោកទទួលខុសត្រូវ។ លោកបន្តថា ជារៀងរាល់ខែ ព្រះសហគមន៍បានធ្វើសិក្ខាសាលាមួយ ក្នុងគោលបំណងដើម្បីឲ្យព្រះសហគមន៍នីមួយៗធ្វើការជាមួយគ្នា និងបង្រៀនទៅតាមអ្វីដែលបានរៀបចំក្នុងសិក្ខាសាលានោះ។

លោក សេង ខេមរិន្ទ ជាគ្រូអប់រំជំនឿនៅព្រះវិហារផ្សារតូចរយៈពេលប្រហែល២ឆ្នាំកន្លះបាននិយាយថា សិក្ខាសាលាដែលលោកបានចូលរួមកន្លងមក ពិតជាឱកាសពិសេសមួយដើម្បីជួបជុំ និងមានទំនាក់ទំនងជាមួយគ្រូអប់រំជំនឿដទៃទៀតនៅក្នុងមណ្ឌលសកម្មភាពទាំងមូលយ៉ាងជិតស្និទ្ធ។ លោកបានបន្តទៀតថា សិក្ខាសាលានេះក៏បានធ្វើឲ្យលោកទទួលបានទាំងចំណេះ ជំនឿ និងគោរុកោសល្យណែនាំយុវជនប្រកបដោយប្រសិទ្ធភាព។

## North Phnom Penh Pastoral Center Catechists Attend Closing Seminar

The seminars which were organized for the catechists in North Phnom Penh Pastoral Center came to a closing seminar. A total of nine seminars were conducted for catechists in 2011-2012.

According to Fr. Bruno Cosme, the North Phnom Penh Pastoral Center really pays much attention to catechism. He added that every month there is a seminar which helps all catechists to prepare and teach what they have decided in each seminar.

Mr. Seng Kemarin, a catechist at St. Joseph Phsar Tauch, said he has taught catechism classes for more than two years and he felt that the seminars were very helpful for him in teaching and in having good relationship with other catechists in the pastoral center of North Phnom Penh. "I've received strategies and I feel confident of what I am doing," said Mr. Kemarin.





# សិស្សសាលាអប់រំជំនឿសន្ត ចាស្ទីនធ្វើទស្សនកិច្ចសិក្

សិស្សសាលាអប់រំជំនឿសន្ត ចាស្ទីនត្រូវបានបែងចែកជាបីក្រុមផ្សេងៗគ្នាដើម្បីធ្វើទស្សនកិច្ចសិក្សានៅប្រទេសចំនួនបី គឺប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសឡាវ។

លោកផុន សុផលជានាយកប្រតិបត្តិសាលា បានឲ្យដឹងថា ក្រុមទីមួយបានធ្វើដំណើរទៅកាន់ប្រទេសវៀតណាមចាប់ពីថ្ងៃ ២៦ ខែកក្កដា ដល់ថ្ងៃទី១ ខែសីហា ដែលដឹកនាំដោយលោកបូជាចារ្យ ប៊្រុយណូ កូសម៍។ ក្រុមទីពីរបានត្រូវធ្វើដំណើរទៅប្រទេសថៃនៅថ្ងៃទី១-៨ ខែសីហា ដែលដឹកនាំដោយលោក បូជាចារ្យ វ៉ាំងសង់។ ចំនែកឯក្រុមទីបីត្រូវទៅប្រទេសឡាវនៅថ្ងៃទី២១-២៩ ខែសីហា ហើយដឹកនាំដោយលោកអភិបាលអូលីវីយេ។ លោកបានបន្ថែមថា ដំណើរទស្សកិច្ចនេះគឺមានគោលបំណងដើម្បីផ្តល់ឱកាសឲ្យនិស្សិតទាំងនោះស្គាល់ព្រះសហគមន៍របស់ប្រទេសជិតខាងខ្លួន និងចង់បង្ហាញថាព្រះសហគមន៍របស់គេជាបងប្អូនរបស់យើងដែរ។ ជាងនេះទៅទៀតគឺដើម្បីឲ្យនិស្សិតចេះប្រៀបធៀបសេដ្ឋកិច្ច វប្បធម៌ នយោបាយរវាងប្រទេសដែលគេបានទៅ និងប្រទេសកម្ពុជា។លោកក៏បានបញ្ជាក់ផងដែរថា ដំណើរទស្សនកិច្ចគឺជាការបំពេញក្រេឌីតនៃមុខវិជ្ជាប្រវត្តិព្រះសហគមន៍។

## សិស្សសាលាអប់រំជំនឿសន្ត ចាស្ទីនធ្វើដំណើរទស្សនកិច្ចសិក្សានៅប្រទេសថៃ


















# សិក្សានៅប្រទេសវៀតណាម ថៃ និងឡាវ

## School of Faith Makes Tour of Churches in Vietnam, Thailand, and Laos

The School of Faith of St. Justin, which was formerly known as the School for the Baptized, is concluding the classes this year with an exposure tour of the Churches and religious places in Thailand, Vietnam and Laos. The 42 students were divided into three groups and each group visited the churches in one of the three countries.

The first group with 19 students went to Vietnam from July 26 to August 1 and it was led by Fr. Bruno COSME. The second group with 19 was in Thailand from August 1-8, and was led by Fr. Vincent SENECHAL. The last group with 9 students would be going to Laos with Bishop Olivier.

Mr. Phon SOPHAL, executive director of the school, said the tour was made to give a special opportunity for students to know and feel that the neighboring churches are their brothers and sisters. He added that this tour would be a good moment for the students to open their eyes to see and compare what the other countries have in common or differently with Cambodia in terms of culture, economics, politics, and so on.

សិស្សសាលាអប់រំជំនឿនៃសន្ត ចាស្ទីនធ្វើដំណើរទស្សនកិច្ចសិក្សា
នៅប្រទេសវៀតណាម




















# ពិធីបុណ្យគម្រប់ ១០០ថ្ងៃ ជូនបងប្រុស ហ្វ្រង់ស៊ីស្កូ សាវីយ៉េ នៅព្រះសហគមន៍សំប៉ាន

ពិធីបុណ្យរំលឹកខួបគម្រប់ ១០០ថ្ងៃ ជូនបងប្រុស ហ្វ្រង់ស៊ីស្កូ សាវីយ៉េ ង្វៀង វ៉ន់គីម បានប្រារព្ធកាលថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ២០១២ នៅព្រះសហគមន៍កាតូលិកសំប៉ាន នៅឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្ដាល។ បងប្រុស ហ្វ្រង់ស៊ីស្កូ សាវីយ៉េ បានទទួលមរណភាព កាលពី ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ ដោយសារជំងឺហឺត ក្នុងវ័យ៣៩ឆ្នាំ។

បងប្រុស ហ្វ្រង់ស៊ីស្កូ សាវីយ៉េ ង្វៀង វ៉ន់គីម បានកើតនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៣ នៅប្រទេសវៀតណាម ហើយបងប្រុសបានចូលរួមក្នុងក្រុមគ្រួសារបេះដូងព្រះយេស៊ូ។ បងប្រុសត្រូវបានចាត់ឲ្យមកប្រទេសកម្ពុជា កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ដើម្បីជួយព្រះសហគមន៍កាតូលិកកម្ពុជា និងជួយក្រុមយុវជននៅមណ្ឌលសកម្មភាពចំប៉ា ភូមិភាគភ្នំពេញ។ បងប្រុសបានស្នាក់នៅព្រះសហគមន៍កាតូលិកសំប៉ាន ព្រមទាំងជួយរាល់សកម្មភាពផ្សេងៗ នៅទីនោះ។ មិន ត្រឹមតែប៉ុណ្ណោះ បងប្រុសបានទៅសុំជំនួយ ពីសប្បុរសជនវៀតណាម យកមក កសាងអគារសាលាមត្តេយ្យ នៅព្រះសហគមន៍កាតូលិកសំប៉ាន ដើម្បីឲ្យកុមារនៅទីនោះបានចូលរៀន។ ហើយបងប្រុសក៏បានទៅជួយព្រះសហគមន៍ កាតូលិកជ្រៃធំរយៈពេល៣ខែ ដើម្បីជួយដល់សកម្មភាពក្នុងព្រះសហគមន៍ឲ្យកាន់តែរីកចម្រើន។

# 100th Day in Memory of Br. Francisco Xavier Ngian Van Kim

The 100th day in memory of Br. Kim was celebrated by Bishop Olivier on July 6 at Sampan Parish, in Kandal Province. Bro. Kim died of asthma on March 30, 2012 at the age of 39.

He was born on March 8, 1973 in Vietnam and he became a member of The Heart of Jesus Society. He came to Cambodia on July 27, 2007 to work with the Phnom Penh vicariate. He stayed at Sampan community and helped in various kinds of activities. Moreover, he raised some money from outside to build a school and kindergarten for kids. He likewise helped the Church in Chrey Thom for three months and then he came back to work at Sampan Parish. There he also helped build a school and the Virgin Mary statue, he visited patients and elders, and delivered some donations to the poor.

***Niroth***





# ការិយាល័យយុវជនត្រៀមរៀបចំមហាសិន្និបាតនៅខែកញ្ញា



ការិយាល័យយុវជន បានអញ្ជើញប្រធានក្រុមយុវជននៅតាមព្រះសហគមន៍នីមួយៗនៅក្នុងភូមិភាគភ្នំពេញបានចូលរួមប្រជុំដើម្បីរៀបចំមហាសិន្និបាតយុវជនភូមិភាគភ្នំពេញនៅដើមខែកញ្ញាខាងមុខនេះ។

លោកផុន សុផល ជាប្រធានការិយាល័យយុវជននិងកុមារមានប្រសាសន៍ថា ប្រធានបទដែលនឹងត្រូវលើកយកពិះគិតក្នុងមហាសិន្និបាតឆ្នាំនេះគឺ ចូររក្សាជំនឿឲ្យបានរឹងប៉ឹង ត្រូវធ្វើឡើងនៅថ្ងៃទី៣-៧ ខែកញ្ញា ឆ្នាំ២០១២ខាងមុខនេះ។ លោកបន្តថា មូលហេតុដែលសម្រេចចិត្តជ្រើសរើសប្រធានបទនេះគឺដោយសារភូមិភាគភ្នំពេញទាំងមូលបានជ្រើសរើសយកឆ្នាំនៅជាមួយព្រះយេស៊ូដើម្បីណែនាំព្រះសហគមន៍ពេញមួយឆ្នាំ។ ដូច្នេះហើយមហាសិន្និបាតនេះគឺ ធ្វើយ៉ាងណាដើម្បីឲ្យយុវជនស្គាល់ព្រះយេស៊ូកាន់តែច្បាស់។

មុននឹងចូលរួមមហាសិន្និបាត ប្រធានក្រុមយុវជនទាំងអស់បានចូលរួមប្រជុំពីរដង។ លើកទីមួយត្រូវបានធ្វើឡើងនៅថ្ងៃទី១៦-១៧ ខែមិថុនា នៅព្រះវិហារបឹងទំពុន។ លើកទីពីរនៅព្រះសហគមន៍ចំប៉ាកាលពីថ្ងៃទី២១-២២ ខែកក្កដា។ ក្នុងកិច្ចប្រជុំនីមួយៗត្រូវបានធ្វើឡើងដើម្បីរៀបចំ និងបែងចែកការទទួលខុសត្រូវការងារប្រចាំថ្ងៃ និងទទួលមេរៀនតាមថ្ងៃនីមួយៗនៅក្នុងមហាសន្និបាត។

## Youth Office Prepares for Youth Synod in Phnom Penh Vicariate

The Youth Office and more than 100 youth leaders from each community in Phnom Penh Vicariate are preparing the program for the coming Youth Synod in September. Two meetings of youth leaders from each community in Phnom Penh Pastoral Center were held earlier: the first was held at Bueng Tumpun on June 16-17 and the final one was held on July 21-22 at Champa parish.

Mr. Phon Sophal, in charge of the Youth Office, said that the Synod would be held on September3-7, 2012 at DON BOSCO Technical School in Phnom Penh Thmey. The theme is “Rooted and Built Up in Jesus Christ, Firm in the Faith”. He added that as we journeyed together with the pastoral year “Be with Jesus”, this theme would help the youth to a better understanding of Jesus our Savior.

Last year the Phnom Penh Vicariate missed to hold the synod because all were involved in the World Youth Day in Madrid, Spain.



# សិស្ស ១៤២នាក់ទទួលវិញ្ញាបនបត្រពីសាលាបណ្តុះបណ្តាលដុនបូស្កូ





សាលាបណ្តុះបណ្តាលដុនបូស្កូបានប្រារព្ធពិធីប្រគល់វិញ្ញាបនបត្រដល់និស្សិតជំនាន់ទី១៨ ចំនួន ១៤២នាក់ កាលពីថ្ងៃទី២១ កក្កដា ២០១២កន្លងទៅនេះ។

ពិធីប្រគល់វិញ្ញាបនបត្រឆ្នាំនេះត្រូវបានធ្វើឡើងរួមគ្នារវាងសាលាដុនបូស្កូអក្ខរកម្ម នឹងកាត់ដេរនៅបាត់ដំបង សាលាដុនបូស្កូទឹកថ្លា និងសាលាដុនបូស្កូផ្នែកលេខាធិកាទួលគោក។

បងស្រីលក្ខិណា យ៉ាវ៉ាសាង ជានាយិកានៃសាលាដុនបូស្កូផ្នែកអក្ខរកម្មនិងកាត់ដេរបានមាន ប្រសាសន៍ថាបេសកកម្មរបស់មជ្ឈមណ្ឌលដុនបូស្កូគឺ ផ្តល់ឲ្យយុវជនមានសេចក្តីសង្ឃឹម និងមានជីវិតរីចំរើនលូតលាស់ ហើយធ្វើឲ្យមានភាពថ្លៃថ្នូរនៅក្នុងជីវិតរស់នៅរបស់គេ តាមរយៈការផ្តល់ការអប់រំ ប្រកបដោយក្តីស្រលាញ់ និងជួយឲ្យពួកគេមានបទពិសោធន៍អំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ដែលជំរុញពួកគេក្លាយទៅជាប្រជាពលរដ្ឋសកម្ម និងមានភាពស្មោះត្រង់។

កញ្ញាហែម ចន្ទា ជាសិស្សសាលាដុនបូស្កូទឹកថ្លា បានប្រាប់ថានាងពិតជាមានអារម្មណ៍រំភើបមែនទែន ដែលនាងមានឱកាសដើម្បីសិក្សានៅសាលាដុនបូស្កូ ជាមួយបងស្រី ហើយអ្វីដែលកាន់តែជាពិសេសថែមទៀតនោះ គឺការទន្ទឹមរង់ចាំថ្ងៃទទួលសញ្ញាប័ត្រនេះ។

គួរបញ្ជាក់ផងដែរតាំងពីវគ្គទី១រហូតមកដល់វគ្គទី១៧នេះ សាលាដុនបូស្កូមានសិស្សដែលបានទទួល វិញ្ញាបនប័ត្រសរុបទាំងបីផ្នែកមានចំនួន ១៥១៤នាក់ ។

## 142 Students Graduate from Salesian Sisters Training Centers

The 18th batch of graduates consisting of 142 students graduated from the three vocational training centers of the Salesian Sisters of Don Bosco this year. The official graduation ceremony was held at the Teuk Thla center last July 21st.

This year's guest speaker was Mr. Kim Rattana, Executive Director of Caritas-Cambodia. Also present on the occasion was the Caritas Chairman, Msgr. Kike Figaredo, Bishop of Battambang, who presided at the graduates' Mass of Gratitude.

Sr. Lakana Yawasang, Director of the girls' center in Battambang, said that all the Don Bosco centers aim to provide the youth with hope and develop their lives by providing them the best quality of education. If young women have knowledge, skills and good values in life, they can contribute much to society and be honest and productive citizens.

Ms. Hem Chenda, a new graduate from Tek Thla, said she had a great fortune that she could study at Don Bosco. " I waited for this chance for two years; and now it has come," said Chenda. She added that Don Bosco has a right vision and mission that can lead students to have a bright future.

# វិទ្យាស្ថានសន្តប៉ូល ស្វាគមន៍និស្សិតថ្មីដើម្បីសិក្សាថ្នាក់បរិញ្ញាបត្រ





វិទ្យាស្ថានសន្តប៉ូលកំពុងជ្រើសរើសនិស្សិតឲ្យសិក្សាកម្មវិធីបរិញ្ញាបត្រសម្រាប់ឆ្នាំសិក្សា ២០១២-២០១៣ ខាងមុខនេះ។ និស្សិតអាចជ្រើសមុខវិទ្យាសិក្សាថ្នាក់បរិញ្ញាបត្របួនគឺ បរិញ្ញាបត្រពត៌មានវិទ្យា បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបរិញ្ញាបត្រក្សេត្រសាស្ត្រ។

វិទ្យាស្ថានសន្តប៉ូល បានបង្កើតបណ្ណាល័យធំទូលាយដែលមានសៀវភៅរាប់ពាន់ក្បាល ហើយបំពាក់អ៊ីនធឺណែតដើម្បីឲ្យនិស្សិត និងសាស្ត្រចារ្យសិក្សាស្រាវជ្រាវ។ វិទ្យាស្ថានសន្តប៉ូលបានសម្រួលឲ្យនិស្សិតក្នុងកំឡុងពេលសិក្សាដោយបង្កើតឲ្យមានអគាស្នាក់នៅដោយឥតគិតថ្លៃ ផ្តល់អាហារថ្ងៃត្រង់ក្នុងម្លៃតែ១២០០រៀល និងកម្មវិធីផ្សេងៗទៀតដែលអាចជួយឲ្យនិស្សិតទទួលបានទាំងចំណេះដឹង និងគុណធម៌សម្រាប់រស់នៅក្នុងជីវិតប្រចាំថ្ងៃ។

វិទ្យាស្ថានមានកិច្ចសហប្រត្តិការជាមួយសាកលវិទ្យាល័យក្នុងប្រទេស និងក្រៅប្រទេសមួយចំនួនដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង សាលាពហុបច្ចេកវិទ្យា សាកលវិទ្យាNGEE ANN នៅប្រទេសសិង្ហបុរី សាកលវិទ្យាល័យកាតូលិក DAEGU នៅប្រទេសកូរ៉េ CISCO Networking Academic និងសាលា Connected School.

វិទ្យាស្ថាននិងមានកម្មវិធីផ្តល់អាហារូបករណ៍ចំនួន២៥០ដុល្លា និងទទួលបានសេវាកម្មដឹកជញ្ជូនទៅមកនិងការប្រើប្រាស់អ៊ីនធឺណែតដោយឥតគិតថ្លៃ ចំពោះនិស្សិតដែលចុះឈ្មោះភ្លាមៗបន្ទាប់ពីលទ្ធផលប្រលងបាក់ឌុបចប់។ វិទ្យាស្ថានសន្តប៉ូលចាប់ផ្តើមទទួលពាក្យចូលរៀនចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ហើយចូលរៀនវគ្គបំប៉ននៅខែកញ្ញាខាងមុខនេះ។ ឆមាសទីមួយនឹងចាប់ផ្តើមចូលរៀននៅខែវិច្ឆិការ។

ពត៌មានបន្ថែមសូមទាក់ទងជាមួយវិទ្យាស្ថានសន្តប៉ូលភូមិអង្គគគីរឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ( ខាងជើងផ្សារអង្គតាសោមចង្ងាយ៣គីឡូម៉ែត្រ ) ។ ទូរស័ព្ទ: ០៣២ ៦៣៩ ០០០៣







# សម្រង់សេចក្តីអធិប្បាយព្រះបន្ទូល របស់លោកអភិបាលអូលីវីយេ ឝ្មិតអ៊ីស្លែរ ក្នុងពិធីសម្ពោធឆ្លំព្រះនាងម៉ារីនៅព្រៃធំ ថ្ងៃទី ៤/០៨/២០១២

**១. សូមថ្លែងព្រះគម្ពីរដំណឹងល្អតែងដោយសន្តយ៉ូហាន ០៥/០៨/២០១២**

ថ្ងៃនេះព្រះយេស៊ូនៅជាមួយមហាជន យើងឃើញមហាជនដើរតាមព្រះអង្គ គេមកច្រើនដូចយើងនៅថ្ងៃនេះដែរ។ ហេតុអ្វីបានជាគេដើរមករកព្រះយេស៊ូ? គឺដោយសារគេឃ្លានបាយ។ អាទិត្យមុនព្រះយេស៊ូបានចែកនំប៉័ងឲ្យក្រុមមនុស្សរាប់ពាន់នាក់ ថ្ងៃនេះយើងឃើញទៀតគេនាំគ្នាមកទៀតដោយសារគេឃ្លានទៀត។ ប្រហែលគេគិតថាស្រួលមែនទែន គេមកតាមព្រះយេស៊ូ ហើយគេបានម្ហូបឥតគិតលុយមួយពេល។ ប៉ុន្តែព្រះយេស៊ូមិនល្ងង់ទេ ព្រះយេស៊ូយល់ចិត្តរបស់គេយ៉ាងច្បាស់ និងព្រះយេស៊ូមិនខ្លាចគេដែរ។ ព្រះយេស៊ូមានព្រះបន្ទូលថា "ទាំងអស់គ្នាមករកខ្ញុំដើម្បីអ្វី? ដើម្បីញ៉ាំបាយតែប៉ុណ្ណឹង"។ ប៉ុន្តែពេលនោះព្រះយេស៊ូមិនដេញគេទេ ដោយសារធ្លាប់ចិញ្ចឹមគេរាប់ពាន់នាក់ម្តងហើយមិនធម្មតាទេ ឥឡូវនេះគេមកទៀតប្រហែលមួយពាន់នាក់ ដូច្នេះយើងដេញគេ តែព្រះយេស៊ូមិនដេញទេព្រះអង្គគ្មានរបៀបនេះទេ។ ផ្ទុយទៅវិញព្រះយេស៊ូណែនាំ បង្រៀនគេឲ្យគេភ្ញាក់ស្មារតី តើគេត្រូវតែចិញ្ចឹមតែក្រពះតែប៉ុណ្ណឹង ឬគេមករកអ្វីផ្សេង?។

ព្រះយេស៊ូចាប់ផ្តើមបង្រៀនគេ ព្រះយេស៊ូចាប់ផ្តើមនិយាយជាមួយគេ ដើម្បីបំភ្លឺគេ។ មនុស្សមិនត្រូវតែញ៉ាំបាយតែប៉ុណ្ណឹង មនុស្សយើងត្រូវការអ្វីផ្សេងដើម្បីចិញ្ចឹមជីវិតគេ។ មិនមែនតែចិញ្ចឹមក្រពះ តែចិញ្ចឹមបេះដូង ចិញ្ចឹមប្រាជ្ញាចិញ្ចឹមជីវិតរបស់យើងតែម្តង។ ព្រះអង្គបានបង្រៀនគេ ឲ្យគេយល់ថាព្រះយេស៊ូយាងមកមិនមែនគ្រាន់តែ ឲ្យនំប៉័ងតិចតួចឲ្យត្រីតិចតួច ឲ្យគេឆ្អែតមួយពេល ព្រះយេស៊ូយាងមកដើម្បីបំពេញជីវិតរបស់គេឲ្យគេមានកម្លាំងស្ថិតស្ថេរ ឲ្យគេមានជីវិតស្ថិតស្ថេរ ឲ្យគេមានសេចក្តីសង្ឃឹមស្ថិតស្ថេរមិនមែនតែមួយភ្លែតទេ។ ព្រះយេស៊ូបំភ្លឺគេ ព្រះយេស៊ូមិនយាងមកដូចលោកម៉ូសេពីមុន ដែលឲ្យនំម៉ាណាសម្រាប់ចិញ្ចឹមមួយពេល ព្រះយេស៊ូយាងមកប្រទានជីវិតដ៏បរិបូរណ៍។ ដើម្បីមានជីវិតដ៏បរិបូរណ៍នេះគេត្រូវការមានអ្វីខ្លះ? គឺយើងត្រូវការមានជំនឿលើព្រះយេស៊ូ។ ប្រសិនបើបងប្អូននឹកឃើញដល់របៀប ដែលព្រះយេស៊ូព្យាបាលអ្នកជម្ងឺ មានស្ត្រីដែលធ្លាក់ឈាមយូរឆ្នាំហើយ មានលោកបាទីមេដែលមើលមិនឃើញ មានអ្នកខ្វិនជើងខ្វិនដៃ ព្រះយេស៊ូព្យាបាលគេបានដោយសារគេជឿលើព្រះយេស៊ូ។

ព្រះយេស៊ូប៉ុន្មានដងប៉ុន្មានសារមានព្រះបន្ទូលទៅគេថា "សុំទៅចុះជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ"។ ប៉ុន្តែព្រះយេស៊ូមិនអាចព្យាបាលគេបាន ប្រសិនបើគេចេះតែសុំៗដោយមិនស្គាល់ព្រះយេស៊ូ គឺព្រះអង្គព្យាបាលគេបានដោយសារគេមានជំនឿលើព្រះយេស៊ូពិតមែន។ ពេលព្រះយេស៊ូថាចិញ្ចឹមគេដោយទទួលអាហារយ៉ាងស្ថិតស្ថេរ គេត្រូវតែយល់ហើយព្រះយេស៊ូមិនអាចឲ្យនំប៉័ងជារៀងរាល់ថ្ងៃ ដើម្បីចិញ្ចឹមគេអស់មួយជីវិត ព្រះយេស៊ូឲ្យគេអ្វីផ្សេងដើម្បីចិញ្ចឹមជីវិតរបស់គេ។ នឹងគេអាចទទួលប្រសិនបើគេជឿលើព្រះយេស៊ូ ដែលជាជីវិតដែលជាសេចក្តីពិតដែលជាផ្លូវ។

ពីដើមរៀងមក នៅក្នុងប្រវត្តិសាស្ត្រនៃព្រះសហគមន៍ យើងមានបងប្អូនថ្មីដែលមិនដែលស្គាល់ព្រះយេស៊ូ គេចង់ស្វែងរកព្រះបន្ទូលទោះបីសព្វថ្ងៃនៅប្រទេសកម្ពុជា យើងមានយុវជនយើងមានយុវចាស់មួយចំនួន ដែលចង់ស្គាល់ព្រះយេស៊ូ។ ប៉ុន្តែជួនកាល យូរៗម្តងគេមានគំនិតដូចមហាជនដែរ គេចង់ទទួលការសិក្សាឥតគិតលុយ គេចង់ទទួលម្ហូបអាហារដើម្បីចិញ្ចឹមជីវិតគេចង់នេះគេចង់នោះមិនឈប់ទេ។ ប៉ុន្តែយើងត្រូវតែស្វាគមន៍គេដូចព្រះយេស៊ូដែរ ព្រះយេស៊ូមិនបណ្តេញមហាជនទេ ព្រះយេស៊ូទទួលគេទោះបីគេមកសុំម្ហូបអាហារ ព្រះយេស៊ូទទួលគេ ប៉ុន្តែព្រះយេស៊ូបង្រៀនគេ។ យើងត្រូវតែទទួលបងប្អូនទាំងអស់ដែលចង់ស្គាល់ព្រះយេស៊ូ ទោះបីមានមូលហេតុមិនច្បាស់លាស់ នឹងបន្តិចម្តងៗមានមួយចំនួនដែលអាចបើកចិត្តគំនិតដើម្បីទទួលជំនឿនឹងធ្វើដំណើរជាមួយព្រះយេស៊ូពិតមែន។

ថ្ងៃនេះព្រះយេស៊ូត្រាស់ហៅយើងទាំងអស់គ្នា។

ទីមួយឲ្យយើងស្រលាញ់ព្រះយេស៊ូ ដូចព្រះនាងម៉ារី។ ព្រះនាងម៉ារីបានស្រលាញ់ព្រះយេស៊ូរបៀបណា? ព្រះនាងម៉ារីបានទទួលដំណឹងថា ធ្វើជាមាតារបស់ព្រះជាម្ចាស់ មិនធម្មតាទេ ប៉ុន្តែព្រះនាងម៉ារីគេចដែលអួតខ្លួន ព្រះនាងម៉ារីមិនដែលរកផលប្រយោជន៍ផ្ទាល់ខ្លួន ដោយសារគាត់ជាម្ដាយរបស់ព្រះយេស៊ូ។ ព្រះនាងម៉ារី មិនដែលរកកិត្តិយសអង្គុយខាងស្តាំនៅខាងឆ្វេងព្រះយេស៊ូ ព្រះនាងម៉ារីមិនដែលសុំអ្វីសោះសម្រាប់ផ្ទាល់ខ្លួន ទោះបីគាត់ជាម្ដាយរបស់ព្រះយេស៊ូពិតមែន។ យើងអាចនិយាយថា ព្រះនាងម៉ារីមានខ្សែពិសេសបំផុតគឺព្រះយេស៊ូតែម្តង ដែលជាកូនគាត់ ដោយសារពេលយើងមានខ្សែយើងពឹងឲ្យធ្វើនេះធ្វើនោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ ប៉ុន្តែព្រះនាងម៉ារីមិនដែលសុំអីសោះ ព្រះនាងម៉ារីមានចិត្តសុភាពរាបសារមានចិត្តលះបង់ចោលអ្វីទាំងអស់ មានចិត្តដាក់ខ្លួនទាប។ នេះជារបៀប ដែលព្រឹកនេះព្រះយេស៊ូត្រាស់ហៅយើង ឲ្យយើងស្រលាញ់ព្រះអង្គ ដោយចេះលះបង់ចោលផលប្រយោជន៍ ឲ្យយើងចេះស្រលាញ់ព្រះយេស៊ូដោយខិតខំអស់ពីកម្លាំងកាយចិត្ត ស្រលាញ់គ្នាទៅវិញទៅមក។

ទីពីរឲ្យយើងចេះស្រលាញ់ព្រះយេស៊ូ ដោយនឹកឃើញពីអ្វីដែលយើងទទួលបានពីព្រះជាម្ចាស់ និងព្រះសហគមន៍។ ប៉ុន្តែស្រលាញ់ព្រះយេស៊ូដោយមិនគិតផលប្រយោជន៍ផ្ទាល់ខ្លួនពិតមែន។ ព្រះសហគមន៍ជាព្រះសហគមន៍ដ៏វិសុទ្ធស្រាប់ហើយ ដោយសារជាព្រះសហ-គមន៍របស់ព្រះជាម្ចាស់ ប៉ុន្តែបុគ្គលយើងដើរតាមផ្លូវខុសធ្វើអំពើអាក្រក់។ ដូច្នេះយើងធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍ទៅជាព្រះសហគមន៍ដ៏វិសុទ្ធ ដោយសាររបៀបដែលយើងស្រលាញ់គ្នា ដោយសាររបៀបដែលយើងលើកលែងទោសឲ្យគ្នា ដោយសាររបៀបដែលយើងផ្តល់សក្ខីភាពអំពីសេចក្តីពិត។ បងប្អូនដឹង នៅពេលយើងមានជម្ងឺផ្តាសាយយើងការពារ កុំឲ្យបងប្អូននៅជិតយើងឆ្លងផ្តាសាយពីយើង។ ផ្ទុយទៅវិញ សម្រាប់យើងដែលជាក្រុមគ្រីស្តបរិស័ទជាសន្តសន្តិ យើងធ្វើដូចម្តេចដើម្បីឲ្យបងប្អូនឯទៀតៗ ឆ្លងភាពបរិសុទ្ធពីយើងដែរ។ នេះជាចំនុចទីមួយគឺស្រលាញ់ព្រះយេស៊ូដូចព្រះនាងម៉ារី។ ចំនុចទីពីរ គឺខិតខំអញ្ជើញបងប្អូនឯទៀតៗឲ្យជួបជាមួយព្រះយេស៊ូដែរ ព្រះសហគមន៍កាតូលិកយើង មិនអាចរស់នៅដោយសារយើងមានកូនចៅយ៉ាងច្រើនដែលគ្រាន់តែខិតខំធ្វើការរបស់យើងតែប៉ុណ្ណោះ។

ព្រះសហគមន៍កាតូលិកយើង ត្រូវតែប្រកាសដំណឹងល្អដល់បងប្អូនដទៃទៀតដែរ កុំគិតតែគ្នាយើងផ្ទុយទៅវិញ ព្រះសហគមន៍មានជីវិត ដោយសារយើងខិតខំប្រកាសដំណឹងល្អដល់អ្នកដទៃដែរ ដែលមិនធ្លាប់ស្គាល់ព្រះយេស៊ូសោះ។ ចំនុចទីមួយ ដើម្បីប្រកាសដំណឹងល្អដល់អ្នកដទៃ គឺរបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយពួកគេ គឺយើងបង្ហាញសេចក្តីស្រលាញ់អាណិតមេត្តាចំពោះគេ និងចែករំលែកអំណរសប្បាយដែលយើងមាន ដោយសារយើងជាគ្រីស្តបរិស័ទ។ ថ្ងៃនេះយើងឃើញមានបងប្អូនមកច្រើននៅទីនេះ ប៉ុន្តែកុំឲ្យយើងគិតថាវាល្មមហើយ ឲ្យអ្នកទៅផ្សារអាចស្តាប់ព្រះបន្ទូលព្រះយេស៊ូបានតាមរយៈយើង។ ពីដើមមានមហាជនដែលដើរតាមព្រះយេស៊ូសព្វថ្ងៃមហាជននោះនៅកន្លែងណា?។ ហេតុនេះហើយ ខ្ញុំសុំអរព្រះគុណព្រះជាម្ចាស់ សម្រាប់ក្រុមរេហ្ស៊ីញម៉ារីយ៉េ សម្រាប់គ្រីស្តបរិស័ទទាំងអស់ ដែលយកចិត្តទុកដាក់ ទីមួយអធិដ្ឋាន ទីពីរស្រលាញ់ ទីបីចែករំលែកអំណរសប្បាយ និងទីបួនប្រកាសដំណឹងល្អ។ យើងមានប្រហែល១៣ព្រះសហគមន៍ហើយ ដែលយើងមានក្នុងក្រុមនេះហើយ យើងសង្ឃឹមមានបន្ថែមទៀតឲ្យព្រះសហគមន៍នីមួយៗមានក្រុមរេហ្ស៊ីញម៉ារីយ៉េ ឲ្យព្រះសហ-គមន៍នីមួយៗមានក្រុមបេះដូងព្រះយេស៊ូ ឲ្យព្រះសហគមន៍នីមួយៗមានក្រុមកុមារតេរេហ្សាដែរ។

ព្រះសហគមន៍មានជីវិត មិនមែនដោយសារបូជាចារ្យ រឺបងស្រីតែប៉ុណ្ណឹង ព្រះសហ-គមន៍មានជីវិតដោយសារគ្រីស្តបរិស័ទយកចិត្តទុកដាក់ស្រលាញ់ព្រះសហគមន៍ និងបំរើអ្នកដទៃ។ ហេតុនេះហើយខ្ញុំសុំឲ្យបងប្អូនទាំងអស់ ខិតខំធ្វើជាគ្រីស្តបរិស័ទយ៉ាងល្អ ដើម្បីឲ្យព្រះសហគមន៍យើងរីកចំរើន និងព្រះសហគមន៍យើងទៅជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះយេស៊ូ លើទឹកដីប្រទេសកម្ពុជាយើង។ កុំឲ្យយើងភ្លេចអធិដ្ឋាន ស្រលាញ់ បំរើ ប្រកាស់ដំណឹងល្អលើទឹកដីប្រទេសកម្ពុជាយើង នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ យើងជាគ្រីស្តបរិស័ទនេះជាអំណរសប្បាយរបស់យើង នេះជាកិត្តិយសរបស់យើង។

អាម៉ែន។

# សុជាតិ ៖ មណ្ឌលពន្លឺនៃមេត្តាធ្វើឲ្យខ្ញុំស្គាល់ពិភពលោក



កំពុងអង្គុយលើកៅអីទល់មុខកំព្យូទ័រ យើងទាំងអស់គ្នាទំនងជាមិនជឿថា សុជាតិជាយុវជនពិការភ្នែកម្នាក់មកពីខេត្តកំពង់ឆ្នាំង។ ជាដាច់ខាត។ ដោយប្រើដៃស្ទាប និងត្រចៀកស្តាប់ សុជាតិអាចដឹងKey ទាំងអស់នៅលើក្តាចុច សុជាតិអាចប្រើប្រាស់អ៊ីនធឺណែតយ៉ាងល្អប្រសើរ។

សុជាតិបានប្រាប់ឲ្យដឹងថា ចំណេះដឹងទាំងនេះ គឺនៅពេលដែលខ្លួនចូលមកស្នាក់នៅមណ្ឌលពន្លឺនៃមេត្តា ហើយបានទទួលការសិក្សានៅសាលា។ យុវជនសុជាតិអាចប្រើកម្មវិធីអ៊ីម៉ែល Skype និងដោនឡូតកម្មវិធីនានាផងដែរ។ សុជាតិបានបន្តទៀតថាកម្មវិធីមួយដែលខ្លួនកំពុងប្រើនេះ គឺគេជាអ្នកដោនឡូតដោយផ្ទាល់ខ្លួនគេ ហើយបើយើងទិញកម្មវិធីនេះមកតំឡើងលើកំព្យូទ័ររបស់យើងវាពិតជាថ្លៃគួរសមដែរ។ កម្មវិធីគឺជាកម្មវិធីមួយដែលជួយឲ្យអ្នកពិការភ្នែកដឹងថាគេកំពុងស្ថិតនៅត្រង់ណា ព្រោះវាមានសំឡេងណែនាំ។ តាមរយៈសមត្ថភាពអាចប្រើអ៊ីនធឺណែតបាន សុជាតិមានអារម្មណ៍ថា ខ្លួនបានចេញពីពិភពងងឹតចូលក្នុងពិភពថ្មីមួយដែលមនុស្សជំនាន់នេះកំពុងតែឲ្យតម្លៃជាខ្លាំង។

លោកស្រី ស្រីនាងជាអ្នកមើលការខុសត្រូវមណ្ឌលពន្លឺនៃមេត្តាបានប្រាប់ឲ្យដឹងថា ជារៀងរាល់ឆ្នាំមានកុមារប្រមាណជា ៤៥នាក់ បានស្នាក់នៅ ហើយទទួលការអប់រំនៅសាលារដ្ឋ និងសាលាអង្គការមួយចំនួននៅទីក្រុងភ្នំពេញ។ លោកស្រីបានបន្តទៀតថា មណ្ឌលបានស្វាគមន៍ជនពិការទូទៅដូចជា ពិការភ្នែក គថ្លង់ ពិការកាយសម្បទា ដែលមានអាយុក្រោម ២៤ឲ្យស្នាក់នៅ។

មណ្ឌលពន្លឺនៃមេត្តាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ ដោយមានការគាំទ្រពីអង្គការជេស្វីត។ មណ្ឌលនេះមានទីតាំងនៅភូមិបឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

## Socheat : “the Light of Mercy Makes Me See the World”

It is unbelievable that a blind person can use the computer and internet so well. But we can see this clearly in a boy called Socheat, 17, from Kompong Chhnang. Socheat has been staying at the Light of Mercy Center for two years now and he is studying in 6th grade at one NGO, called “Krousa Thmey,” meaning “new family”.

Socheat can use E-mail, skype and download some applications to install on the computer. Consequently, he has downloaded a program which is able to guide the blind with sounds.

Ms. Sreyneang said there are 45 students under the age of 24 who are staying in the center right now. The Light of Mercy is a place that welcomes especially kids who are deaf, blind and physically disabled. The center was established in 1997 under the support of the Jesuits.

## សកម្មភាពលោក សុខកុមារ អូលីវីយេ ផ្មីតអ៊ីស្ស៊ែរ
## អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
## ក្នុងខែ កញ្ញា ឆ្នាំ២០១២

| | |
|---|---|
| ថ្ងៃទី១-២ ខែកញ្ញា | ៖ សួរសុខទុក្ខព្រះសហគមន៍នៅតាកែវ |
| ថ្ងៃទី៣ ខែកញ្ញា | ៖ ប្រជុំសម្ព័ន្ធកាតូលិកដើម្បីមេត្តាករុណា និងអភិវឌ្ឍ |
| ថ្ងៃទី៤-៧ ខែកញ្ញា | ៖ មហាសិន្និបាតយុវជនភូមិភាគភ្នំពេញ |
| ថ្ងៃទី៩ ខែកញ្ញា | ៖ ធ្វើអគ្គសញ្ញាលាបថ្វាសនៅព្រះសហគមន៍សំរោងធំ |
| ថ្ងៃទី១០ ខែកញ្ញា | ៖ ប្រជុំគ្រូបង្រៀននៅសាលាសន្ត ហ្វ្រង់ស្វ័រ |
| ថ្ងៃទី១៣-១៦ ខែកញ្ញា | ៖ បោះជំរុំសម្រាប់កុមារកាយឫទ្ធិនៅគីរីវង្ស |
| ថ្ងៃទី ១៧-១៩ ខែកញ្ញា | ៖ ប្រជុំក្រុមប្រឹក្សាបូជាចារ្យ |
| ថ្ងៃទី២០ ខែកញ្ញា | ៖ គណៈកម្មការកីឡានៅវិទ្យាស្ថានសន្តប៉ូល |
| ថ្ងៃទី២១ ខែកញ្ញា | ៖ ប្រជុំក្រុមបូជាចារ្យ MEP |
| ថ្ងៃទី២២ ខែកញ្ញា | ៖ បុណ្យសន្តហ្វ្រង់ស្វ័រ និងសន្តីតេរេសានៅចំការទៀង |
| ថ្ងៃទី២៤-២៨ ខែកញ្ញា | ៖ មហាសន្និបាតគ្រូអប់រំជំនឿ |
| ថ្ងៃទី២៨-៣០ ខែកញ្ញា | ៖ បើកឆ្នាំសិក្សាឆ្នាំទីពីរនៅសាលាអប់រំគ្រីស្តបរិស័ទនៃសន្តចាស្ទីន |
| ថ្ងៃទី៣០ ខែកញ្ញា | ៖ អភិបូជានៅព្រះវិហារសន្តយ៉ូសែបផ្សារតូច |

## The activities of Bishop Olivier Schmitthaeusler, MEP
## Apostolic Vicar of Phnom Penh,
## September 2012

| | | |
|---|---|---|
| September | 01 -02 | : Visit at Takeo Parish |
| September | 03 | : Catholic Alliance for Development and Charity Meeting |
| September | 0 4 -07 | : Phnom Penh YOUTHS SYNOD |
| September | 09 | : Confirmations at Somrong Thom parish |
| September | 10 | : Meeting with St Francis Teachers |
| September | 13-16 | : Camp and Session for Scouts ( Kirivong parish ) |
| September | 17-19 | : Meeting with Priests Council |
| September | 20 | : Inauguration of the new Sports Court at Saint Paul Institute |
| September | 21 | : MEP meeting |
| September | 22 | : Saint Francis + Sainte Teresa Feast at Chomkar Teang parish |
| September | 24-28 | : Synod for Catechists |
| September | 28-30 | : Opening Session for 2nd year of the School of Faith Saint Justin |
| September | 30 | : Mass at Saint Joseph Parish |

## រូបភាពប្រចាំខែកក្កដា



ព្រះវិហារនៅទីក្រុង LISIEUX ប្រទេសបារាំង



ពិធីសម្ពោធព្រះនាងម៉ារីនៅជ្រៃធំ



អភិបូជា ជាមួយលោកកាឌីណាល់ THEODORE មកពីទីក្រុងវ៉ាស៊ីនតោន



លោកអភិបាលអូលីវីយេ និងបូជាចារ្យប្រ៊ុយណូ ចេញដំណើរទៅប្រទេស បារាំង


ព្រះសហគមន៍ភូមិភាគភ្នំពេញ
ព្រឹត្តិបត្រ ជីវិត
អ្នកទទួលខុសត្រូវ: លោកអភិបាល អូលីវីយេ ស្មិតអ៊ីស្លែរ
Tel: 023 212 462
Email: apostolicvicariate.phnompenh@gmail.com
កាវីនិពន្ធ: ញឹប ញៀន
Email: markgnuen@gmail.com
ការិយាល័យផ្សព្វផ្សាយពត៌មានកាតូលិក
# ២៥ ផ្លូវ២៤២ បឹងព្រលឹត ៧មករា ភ្នំពេញ.

Apostolic vicariate Phnom Penh
LIFE NEWSLETTER
**Chairman:** Msgr. Olivier Schmitthaeusler.
**Tel:** 023 212 462
**Email:** apostolicvicariate.phnompenh@gmail.com
**Editor:** Gneb Gnuen
**Email:** markgnuen@gmail.com
**Catholic Social Communications**
#25, St 242, Boeung Prolit, 7 Makara, Phnom Penh.